**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៧៨៣ សហវ.អថ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្ដីពីការងារស្ថាបនាផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែ ប្រវែង ៦ ១០០ម ទទឹងខ្នងលើ ០៧ម សាងសង់លូប្រអប់ចំនួន ០១កន្លែង និងសាងសង់លូមូលចំនួន ០៥កន្លែង ស្ថិតនៅខេត្តកំពត។

**យោង:** - លិខិតលេខ ៦២២៣ សហវ.អថ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ១០១៧/១៧ ក.អ.ជ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែ ប្រវែង ៦ ១០០ម ទទឹងខ្នងលើ ០៧ម កម្រាស់ 0,២ម សាងសង់លូប្រអប់មុខបីទំហំ ១០,៥ម កម្ពស់ ៣,៥ម ប្រវែង ០៨ម ចំនួន ០១កន្លែង លូមូលមុខមួយទំហំ ១០០ស.ម ប្រវែង ០៨ម ចំនួន ០៥កន្លែង ស្ថិតនៅភូមិមនោសុខ ទៅភូមិជ័យតាស្វាយ ឃុំតាកែន ស្រុកឈូក ខេត្តកំពត ក្នុងតម្លៃសរុបចំនួន ១ ៩៨៧ 000 000រៀល (មួយពាន់ប្រាំបួនរយប៉ែតសិបប្រាំពីរលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឲ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឲ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ក.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**ជួ ឧិជីត្ត**

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានផ្លូវលំជនបទ
- សាលាខេត្តកំពត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពត
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត
- ឯកសារ-កាលប្បវត្តិ